ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
( ASPIRE )

# គោលការណ៍វេទិកាសាធារណៈថ្នាក់ស្រុក
# District Forum Guidelines

រៀបចំដោយ : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
ឧបត្ថម្ភដោយ: កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

ភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៧

Reference #.........................
Version: 001

# មាតិកា


សេចក្តីផ្តើម .... 3
១ ពេលវេលា .... 3
២ ទីកន្លែង .... 3
៣ ប្រធានបទទេវិកាសាធារណៈ .... 3
៤ អ្នកចូលរួម .... 4
៥ គណៈអធិបតី .... 4
៦ វាគ្មិន .... 4
៧ អ្នករៀបចំ .... 4
៨ អ្នកសម្របសម្រួល .... 5
៩ ឯកសារជំនួយស្មារតី .... 5

គំរូឯកសារជំនួយស្មារតី .... 5
សេចក្តីផ្តើម .... 5
១ គោលបំណង .... 5
២ លទ្ធផលរំពឹងទុក .... 6
៣ អ្នកចូលរួម .... 6
៤ វាគ្មិន .... 7
៥ អ្នកសម្របសម្រួល .... 7
៦ កម្មវិធី .... 8


DRAFT

Reference #.........................
Version: 001

# សេចក្តីផ្តើម

យោងទៅតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា វេទិកាសាធារណៈថ្នាក់ស្រុកគឺជាផ្នែកមួយសម្រាប់ ការធ្វើឲ្យប្រសើរនូវសេវាផ្សព្វផ្សាយដែលបានផ្តល់នៅថ្នាក់ស្រុក និងថ្នាក់ខេត្ត។ វេទិកាសាធារណៈ គឺត្រូវការសហការរវាងបណ្តាញ និងក្រុមគាំទ្របច្ចេកទេសកសិកម្មថ្នាក់ខេត្តមាន ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទជាអនុប្រធាន ក្រុមគាំទ្របច្ចេកទេសថ្នាក់ស្រុក ដែលមានអភិបាលស្រុកជាប្រធាន អង្គការក្រៅរដ្ឋាភិបាល មន្ត្រីការិយាល័យកសិកម្មស្រុក ភ្នាក់ងារផ្សព្វផ្សាយឃុំ អង្គការសហប្រជាជាតិ ផ្នែកជន សហគមន៍អភិវឌ្ឍន៍កសិកម្ម និងក្រុមកសិករ។

គោលការណ៍ណែនាំនេះមានគោលបំណងផ្តល់ការអប់រំ ថាតើត្រូវរៀបចំ និងដំណើរការវេទិការសាធារណៈថ្នាក់ស្រុកនៅថ្នាក់ស្រុកយ៉ាងដូចម្តេច។ ដូច្នេះហើយសម្រាប់អ្នកអនុវត្តត្រូវចាប់ផ្តើមវេទិការសាធារណៈមានប្រាំបួនជំហាន ដូចខាងក្រោមៈ

## ១.ពេលវេលា

វេទិការសាធារណៈគួរចាប់ផ្តើមរវាងខែ មេសា និងខែ កក្កដា ជារៀងរាល់ឆ្នាំ ដើម្បីផ្តល់ឱកាសសម្រាប់កសិករ ផ្នែកឯកជនលក់សម្ភារៈកសិកម្ម អ្នកប្រមូលទិញ អ្នកទិញ និងអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីផលិតផល និងតម្រូវការទីផ្សារ។ ដូច្នេះពេលវេលាអាចត្រូវបានផ្លាស់ប្តូរ គឺប្រែប្រួលទៅតាមស្ថានភាពក្នុងស្រុកនីមួយៗ។

## ២.ទីកន្លែង

វេទិការសាធារណៈថ្នាក់ស្រុកគួរតែធ្វើឡើងនៅការិយាល័យកសិកម្មស្រុក ឬ សាលាស្រុក។

## ៣.ប្រធានបទវេទិការសាធារណៈ

វេទិការសាធារណៈថ្នាក់ស្រុកគួរតែពិភាក្សានូវប្រធានបទដូចខាងក្រោមនេះ:

- ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ទៅលើកសិកម្ម ការប្រកបរបរចិញ្ចឹមជីវិត ហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការទីផ្សារ
- ឱកាស បញ្ហា និងដំណោះស្រាយ អំពីតម្រូវការទីផ្សារ អ្នកផ្គត់ផ្គង់ តម្លៃ គុណភាព បរិមាណនៃផលិតផល និងខ្នាតគម្រូនៃផលិតផលកសិកម្ម (GAP, CAMGAP ផលិតផលកសិកម្មសរីរាង្គ.........)
- កិច្ចសហប្រតិបត្តការរវាងតួអង្គផ្សេងៗក្នុងចង្វាក់ទីផ្សារ ឈ្មួញកណ្តាល កសិករ អ្នកទិញ អាជ្ញាធរ មន្ត្រីផ្សព្វផ្សាយ ភ្នាក់ងារផ្សព្វផ្សាយឃុំ និងផ្នែកឯកជនលក់សម្ភារៈកសិកម្ម។

## ៤.អ្នកចូលរួម

អ្នកដែលត្រូវអញ្ជើញចូលរួមក្នុងវេទិការសាធារណៈមាន:

១. មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

២.ការិយាល័យកសិកម្មស្រុក/ភ្នាក់ងារផ្សព្វផ្សាយឃុំ

៣.អង្គការក្រៅរដ្ឋាភិបាល/អង្គការសហប្រជាជាតិ/អង្គការអន្តរជាតិ

៤.កសិករឆ្នើម/ ប្រធានសហគមន៍អភិវឌ្ឍន៍កសិកម្ម

៥.វាគ្មិន

៦.ទីប្រឹក្សាគ្រប់គ្រងអនុកម្មវិធីថ្នាក់ខេត្ត និងទីប្រឹក្សាតាមដាន និងវាយតម្លៃ/ប្រព័ន្ធគ្រប់គ្រងទិន្នន័យ

៧.គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD)

៨.ស្ថាប័នមីក្រូហិរញ្ញវត្ថុ/ធនាគារ (ស្ថាប័នមីក្រូហិរញ្ញវត្ថុដែលធ្វើការងារជាមួយកសិករខ្នាតតូច)

៩.អាជ្ញាធរមូលដ្ឋាន (មេភូមិ ក្រុមប្រឹក្សាឃុំ និងអភិបាលស្រុក)។

## ៥.គណៈអធិបតី

ក្រុមគាំទ្របច្ចេកទេសថ្នាក់ស្រុក(អភិបាលស្រុក)/អនុប្រធានក្រុមគាំទ្របច្ចេកទេសថ្នាក់ខេត្ត នឹងត្រូវបានអញ្ជើញចូលរួមសម្រាប់បើកកម្មវិធីប្រជុំ។

## ៦.វាគ្មិន

វាគ្មិន និងត្រូវបានអញ្ជើញចូលរួមវេទិការសាធារណៈមកពី:

- មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ/ការិយាល័យកសិកម្មស្រុក
- កសិករឆ្នើម
- អង្គការក្រៅរដ្ឋាភិបាល
- ផ្នែកឯកជន

## ៧.អ្នករៀបចំ

ទីប្រឹក្សាតាមដាន វាយតម្លៃ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងមន្ត្រីដៃគូរនិងទទួលខុសត្រូវ សម្រាប់ការរៀបចំកត់ត្រាការពិភាក្សា និងធ្វើកំណត់ហេតុនៃលទ្ធផលវេទិការសាធារណៈ។ កំណត់ហេតុនិងត្រូវផ្ញើរជូនអ្នកពាក់ព័ន្ធទាំងអស់បន្ទាប់ពីដំណើរការវេទិការសាធារណៈមួយសប្តាហ៍។



DRAFT

## ៨.អ្នកសម្របសម្រួល

អ្នកសម្របសម្រួលនៃវេទិកាសាធារណៈគឺក្រុមការងារមកពីៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម/មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទ) ។

ក្រុមការងារមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំលិខិតអញ្ជើញ និងផ្ញើរជូនគ្រប់អ្នកពាក់ព័ន្ធយ៉ាតិច ៣សប្តាហ៍មុនវេទិការសាធារណៈចាប់ផ្តើម។

## ៩. ឯកសារជំនួយស្មារតី

ទីប្រឹក្សាគ្រប់គ្រងអនុកម្មវិធីថ្នាក់ខេត្ត និងមន្រ្តីតាមដានជាដៃគូរ និងទទួលខុសត្រូវ ក្នុងការរៀបចំឯកសារជំនួយស្មារតី និងផ្ញើរជូនក្រុមការងារ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ដើម្បីពិនិត្យនិងផ្តល់ធាតុចូល។ ឯកសារជំនួយស្មារតី គួរតែបានបញ្ចប់ក្នុងរយះពេលមួយខែមុននឹង ដំណើរការវេទិការសាធារណៈចាប់ផ្តើម។

# គំរូឯកសារជំនួយស្មារតី

## សេចក្តីផ្តើម

យោងទៅតាមគោលនយោបាយផ្សាយកសិកម្មនៅកម្ពុជា វេទិកាសាធារណៈថ្នាក់ស្រុកគឺជាផ្នែកមួយសម្រាប់ការធ្វើឲ្យប្រសើរនូវសេវាផ្សព្វផ្សាយដែលបានផ្តល់នៅថ្នាក់ស្រុក និងថ្នាក់ខេត្ត។ វេទិកាសាធារណៈ គឺត្រូវការសហការរវាងបណ្តាញ និងក្រុមគាំទ្របច្ចេកទេសកសិកម្មថ្នាក់ខេត្តមាន ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទជាអនុប្រធានក្រុមគាំទ្របច្ចេកទេសថ្នាក់ស្រុក ដែលមានអភិបាលស្រុកជាប្រធាន អង្គការក្រៅរដ្ឋាភិបាល មន្រ្តីការិយាល័យ កសិកម្មស្រុក ភ្នាក់ងារផ្សព្វផ្សាយឃុំ អង្គការសហប្រជាជាតិ ផ្នែកជន សហគមន៍អភិវឌ្ឍន៍កសិកម្មនិងក្រុមកសិករ។

## ១.គោលបំណង

- ឱកាស បញ្ហា និងដំណោះស្រាយ អំពីតម្រូវការទីផ្សារ អ្នកផ្គត់ផ្គង់ តម្លៃ គុណភាព បរិមាណនៃផលិតផល និងខ្នាតគម្រូនៃផលិតផលកសិកម្ម (GAP, CAMGAP ផលិតផលកសិកម្មសរីរាង្គ.........)
- ប្រសិទ្ធភាពនៃការផ្សព្វផ្សាយ
- ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ទៅលើកសិកម្ម ការប្រកបរបរចិញ្ចឹមជីវិត ហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការទីផ្សារ។
- កិច្ចសហប្រតិបត្តការរវាងតួអង្គតម្លៃ ឈ្មួញកណ្តាល កសិករ អ្នកទិញ អាជ្ញាធរ មន្រ្តីផ្សព្វផ្សាយ ភ្នាក់ងារផ្សព្វផ្សាយឃុំ និងផ្នែកឯកជនលក់សម្ភារៈកសិកម្ម។

## ២.លទ្ធផលសង្ឃឹមទុក

- មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ការិយាល័យកសិកម្មស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ បានយល់ច្បាស់ពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយ និងកែលម្អឡើងវិញយ៉ាងប្រសើរ
- រៀបចំអាទិភាពដើម្បីដោះស្រាយផលប៉ះពាល់ របស់ការប្រែប្រួលអាកាសធាតុទៅលើកសិកម្ម ការប្រកបរបរចិញ្ចឹមជីវិត ហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការទីផ្សារ
- កសិករមានទំនុកចិត្តក្នុងការដាំដំណាំ និងបង្កើនផលិតកម្ម និងផលិតភាពកសិកម្ម របស់គាត់ច្រើនមុខត្រូវតាមតម្រូវការទីផ្សារ និងតម្លៃទីផ្សារ
- បង្កើនការសហការរវាង តួអង្គផ្សេងៗក្នុងចង្វាក់ទីផ្សារ ឈ្មួញកណ្តាល។

## ៣.អ្នកចូលរួម

**អ្នកចូលរួមសវេទិការសាធារណៈមានមកពីៈ**

| ល.រ | ស្ថាប័ន | ចំនួន (នាក់) |
|---|---|---|
| I | **ថ្នាក់ខេត្ត/មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ** | |
| ១ | ប្រធាន ឬអនុប្រធានមន្ទីរកសិកម្មខេត្ត | ១ |
| ២ | មន្ត្រីក្សេត្រសាស្ត្រ | ១ |
| ៣ | មន្ត្រីផលិតកម្ម និងបសុព្យាបាល | ១ |
| ៤ | មន្ត្រីផ្សព្វផ្សាយកសិកម្ម | ១ |
| ៥ | មន្ត្រីតាមដាន និងវាយតម្លៃ | ១ |
| ៦ | ទីប្រឹក្សាគ្រប់គ្រងអនុ-កម្មវិធីថ្នាក់ខេត្ត | ១ |
| ៧ | ទីប្រឹក្សាតាមដាន និងវាយតម្លៃ/គ្រប់គ្រងប្រព័ន្ធព័ត៌មានថ្នាក់ខេត្ត | ១ |
| II | **ថ្នាក់ស្រុក/ការិយាល័យកសិកម្មស្រុក** | |
| ៨ | ប្រធានការិយាល័យកសិកម្មស្រុក | ១ |
| ៩ | មន្ត្រីក្សេត្រសាស្ត្រ | ១ |
| ១០ | មន្ត្រីផលិតកម្ម និងបសុព្យាបាល | ១ |
| ១១ | មន្ត្រីផ្សព្វផ្សាយកសិកម្ម | ១ |
| ១២ | មន្ត្រីសហគមន៍កសិកម្ម | ១ |
| ១៣ | ភ្នាក់ងារផ្សព្វផ្សាយឃុំ | ៦ |
| III | **ផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាល** | |
| ១៣ | អង្គការក្រៅរដ្ឋាភិបាល | ៣ |

| | | |
|---|---|---|
| ១៤ | ផ្នែកឯកជន | ៣ |
| **IV** | **អាជ្ញាធរមូលដ្ឋាន** | |
| ១៥ | អភិបាលស្រុក | ១ |
| ១៦ | ក្រុមប្រឹក្សាឃុំ | ៦ |
| ១៧ | ប្រធានភូមិ | ១០ |
| **V** | **សហគមន៍** | |
| ១៨ | កសិករឆ្នើម | ៦ |
| ១៩ | សហគមន៍អភិវឌ្ឍន៍កសិកម្ម | ២ |
| ២០ | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម | ៣ |
| | **សរុប** | **៥២** |

## ៤.ខាឃ្មិន

**វាឃ្មិនដែលត្រូវអញ្ជើញចូលរួមវេទិការសាធារណៈមាន:**

| លរ | ស្ថាប័ន | ចំនួន (នាក់) |
|---|---|---|
| ១ | ប្រធានការិយាល័យកសិកម្មស្រុក | ១ |
| ២ | ប្រធានឬ អនុប្រធាន មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ១ |
| ៣ | អង្គការក្រៅរដ្ឋាភិបាល | ៣ |
| ៤ | ផ្នែកឯកជន | ៣ |
| ៥ | អភិបាលស្រុក | ១ |
| ៦ | កសិករឆ្នើម | ១ |
| | **សរុប** | **១០** |

## ៥.អ្នកសម្របសម្រួល

| លរ | ស្ថាប័ន | ចំនួន (នាក់) |
|---|---|---|
| ១ | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋាន កសិកម្ម | ២ |
| ២ | មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ២ |
| ៣ | ទីប្រឹក្សាគ្រប់គ្រងអនុ-កម្មវិធីថ្នាក់ខេត្ត | ១ |
| ៤ | មន្ត្រីតាមដាន និងវាយតម្លៃ | ១ |
| | **សរុប** | **៦** |

# ៦.កម្មវិធី

| កាលបរិច្ឆេទ/ម៉ោង | សកម្មភាព | អ្នកសម្របសម្រួល |
| --- | --- | --- |
| ០៧:៣០-០៨:០០ | - ចុះវត្តមាន | មន្ត្រីតាមដាន និងវាយតម្លៃ |
| ០៨:០០-០៨:១៥ | - គោរពទង់ជាតិ,បង្ហាញកម្មវិធី គោលបំណងនៃកិច្ចប្រជុំ | មន្ត្រីតាមដាន និងវាយតម្លៃ |
| ០៨:១៥-០៨:៣០ | - បើកម្មវិធី | អភិបាលស្រុក |
| ០៨:៣០-០៩:០០ | - របាយការណ៍ អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដល់សកម្មភាពកសិកម្មក្នុងតំបន់ស្រុកគោលដៅ និងការអន្តរាគមន៍ពីការិយាល័យកសិកម្មស្រុក និងអាជ្ញាធរមូលដ្ឋាន (កសិកម្ម,ចំណាកស្រុក, ទីផ្សារ,ការទំនាក់ទំនង ជាមួយឈ្មួញកណ្តាល និងកសិករ)។ | ប្រធានការិយាល័យកសិកម្មស្រុក |
| ០៩:០០-០៨:៣០ | - សំណួរ -ចម្លើយ | ការពិភាក្សាពេញអង្គ |
| **០៩:៣០-០៩:៤៥** | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥-១០:០០ | - បទពិសេធន៍នៃការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់ផលិតកម្មកសិកម្ម របស់កសិករ | តំណាងកសិករឆ្នើម |
| ១០:០០-១០:៣០ | - បទពិសោធន៍នៃការគាំទ្របច្ចេកទេសរបស់អង្គការក្រៅរដ្ឋាភិបាលចំពោះកសិករឆ្លើយតបទៅនិងការប្រែប្រួលអាកាសធាតុប៉ះពាល់ទៅផលិតកម្មកសិកម្ម | តំណាងអង្គការក្រៅរដ្ឋាភិបាល |
| ១០:៣០-១១:០០ | - បទពិសោធន៍នៃការផ្តល់សេវាដោយផ្នែកឯកជន ក្នុងការគាំទ្រកសិករ ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ | តំណាងផ្នែកឯកជន |
| ១១:០០-១២:០០ | - សង្ខេបលទ្ធផល និងបទពិសោធន៍នៃការបង្ហាញ<br>- សំណួរ -ចម្លើយ ដំណោះស្រាយ និងចាត់អាទិភាព | ទីប្រឹក្សាគ្រប់គ្រងអនុ-កម្មវិធីថ្នាក់ខេត្ត |
| **១២:០០-១៣:៣០** | **ពិសារបាយថ្ងៃត្រង់** | |

| | | |
|---|---|---|
| ១៣:៣០-១៤:១៥ | **ការពិភាក្សាតាមក្រុម៖**<br>- **ក្រុមទី១: ការពិភាក្សាអំពីតម្រូវការទីផ្សារ (ផលិតផល តម្លៃទីផ្សារ ឧបសគ្គ)។** អ្នកចូលរួម៖ ឈ្មួញកណ្ដាល អ្នកទិញសំខាន់ៗ សហគមន៍អភិវឌ្ឍន៍កសិកម្ម<br>- **ក្រុមទី២: ការពិភាក្សាអំពី ផលិតផល និងការផ្គត់ផ្គង់ (ផលិតផល,ទំនិញ,ការប្រកួតប្រជែង ,ឧបសគ្គ)** អ្នកចូលរួម៖ កសិករ សហគមន៍អភិវឌ្ឍន៍កសិកម្ម<br>- **ក្រុមទី៣: ការពិភាក្សា អំពីសម្ភារផ្គត់ផ្គង់ ដល់សហគមន៍**<br>- អ្នកចូលរួម៖ អ្នកផ្គត់ផ្គង់ និងផ្នែកឯកជន | ក្រុមទី១: អគ្គនាយកដ្ឋានកសិកម្ម<br><br>ក្រុមទី២: មន្ទីរកសិកម្ម<br><br>ក្រុមទី៣: ការិយាល័យកសិកម្មស្រុក |
| ១៤:១៥-១៤:៣០ | - តំណាងក្រុមឡើងបង្ហាញ<br>- សំណួរ-ចម្លើយ | តំណាងក្រុមទី ១ ២ ៣ |
| **១៤:៣០-១៤:៤៥** | **សម្រាកពិសារអាហារសម្រន់** | |
| ១៤:៤៥-១៥:៣០ | - **ការពិភាក្សាពេញអង្គ៖** អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នរាជរដ្ឋាភិបាល អន្តរាគមន៍ក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើងដោយ កសិករ និងតួអង្គផ្សេងៗក្នុងខ្សែចង្វាក់ទីផ្សារ | វាឃ្មិន |
| ១៥:៣០-១៥:៤៥ | - ការវាយតម្លៃ | ទីប្រឹក្សា និងមន្ត្រីតាមដាន និងវាយតម្លៃ |
| ១៥:៤៥-១៦:០០ | - បូកសរុប និងបិទកម្មវិធី | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

DRAFT